# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម ជស/រកម/០៧៩៩/០១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ជស/រកម០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការងារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ប្រកាសឲ្យប្រើ

ច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុសញ្ញាលេខ ១៥០ ស្ដីពីរដ្ឋបាលការងារនៃអង្គការអន្តរជាតិខាងការងារ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

## ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើអនុសញ្ញាលេខ ១៥០ ស្ដីពី

## រដ្ឋបាលការងារ នៃអង្គការអន្តរជាតិខាងការងារ

**មាត្រា ១.**_ អនុម័តយល់ព្រមលើអនុសញ្ញាលេខ ១៥០ ស្ដីពីរដ្ឋបាលការងារ នៃអង្គការអន្តរជាតិខាងការងារ ដែលត្រូវបានអនុម័តដោយមហាសន្និបាត នៃអង្គការអន្តរជាតិខាងការងារ នៅហ្សឺណែវ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៨ ហើយដែលមានអត្ថបទទាំងស្រុងជូនភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.**_ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជា

ប្រមុខរដ្ឋ ស្ដីទី

ហត្ថលេខា

ជា ស៊ីម

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ

និងអតីតយុទ្ធជន

ហត្ថលេខា

អ៊ិត សំហេង